**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៣០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១** : អនុក្រឹត្យនេះកំណត់បេសកកម្ម និង ការរៀបចំរចនាសម្ព័ន្ធ បណ្តាអង្គភាពនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ( គ.ជ.គ.ម ឬ NCDM ) ។

# ជំពូកទី២
# បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា២ :** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្ម អោយដឹកនាំការងារគ្រប់គ្រងគ្រោះមហន្តរាយនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ :** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយមានមុខងារ និងភារកិច្ចដូចតទៅ :

- ធ្វើការសំរបសំរួល ជាមួយក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ សមាគមជាតិនានា និងសប្បុរសជនក្នុងស្រុក ដើម្បីកៀរគរជំនួយសំរាប់ឆ្លើយតបសង្គ្រោះបន្ទាន់និងស្តារឡើងវិញ ។
- ផ្តល់យោបល់ ជូនរាជរដ្ឋាភិបាល ដាក់ចេញគោលការណ៍គោលនយោបាយសំខាន់ៗ សេចក្តីប្រកាសដើម្បីត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងវិធានការណ៍ ឆ្លើយតបសង្គ្រោះ បន្ទាន់ ការធ្វើអន្តរាគមន៍ប្រជាជនទៅរកទីទួលសុវត្ថិភាព ។
- ផ្សព្វផ្សាយការងារគ្រប់គ្រងគ្រោះមហន្តរាយ ដល់សហគមន៍ និងពង្រឹងខ្សែបណ្តោយ ពីថ្នាក់ជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធរហូតដល់ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ព្រមទាំងបណ្តុះបណ្តាលធនធានមនុស្សដើម្បីបង្កើនសមត្ថភាពការងារគ្រប់គ្រងគ្រោះមហន្តរាយ អោយកាន់តែរឹងមាំ និង មានប្រសិទ្ធភាព ។
- លើកសំណើជូនរាជរដ្ឋាភិបាល អំពីការត្រៀមបំរុងនូវ មូលនិធិ សំភារៈ ប្រេងឥន្ធនៈ មធ្យោបាយធនធានមនុស្ស ដើម្បីត្រៀមបង្ការ និងធ្វើអន្តរាគមន៍ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ មុនពេល ក្នុងពេល និងក្រោយពេល កើតមានគ្រោះមហន្តរាយ ដើម្បីភាពម្ចាស់ការជាមុន ។

**មាត្រា ៤ :** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយមានគណៈកម្មការប្រតិបត្តិមួយ សំរាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- ប្រធាន | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ២- អនុប្រធានទី១ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៣- អគ្គលេខាធិការ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |

**មាត្រា ៥:** មន្ត្រីរាជការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយជាមន្ត្រីរាជការដែលមានក្របខ័ណ្ឌស្រាប់ និងស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

ថវិកានៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាផ្នែកមួយនៃថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រីដែលមានកញ្ចប់ថវិកាដោយឡែករបស់ខ្លួននិងស្ថិតក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយមានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន។

**មាត្រា ៦:** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវកោះប្រជុំសាមញ្ញ យ៉ាងតិច ៦ខែម្តង។

**មាត្រា ៧:** គណៈកម្មការប្រតិបត្តិនៃ (គ.ជ.គ.ម) ត្រូវធ្វើការប្រជុំមួយខែម្តង ។

**មាត្រា ៨:** ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយអាចនិងកោះប្រជុំវិសាមញ្ញរបស់ខ្លួន និងរបស់គណៈកម្មការប្រតិបត្តិ (គ.ជ.គ.ម)។

**មាត្រា ៩:** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មាន រចនាសម្ព័ន្ធ ដូចតទៅ :

- ខុទ្ទកាល័យ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- អគ្គលេខាធិការដ្ឋាន រួមមាន នាយកដ្ឋាន ៥ :
  - នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ
  - នាយកដ្ឋាន ពត៌មាន និង ទំនាក់ទំនង
  - នាយកដ្ឋាន ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ
  - នាយកដ្ឋាន ត្រៀមរៀបចំ និងបណ្តុះបណ្តាល
  - នាយកដ្ឋានសំរបសំរួល ការងាររុករក ឧបទ្ទវហេតុ យន្តហោះ និងនាវា
- ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយក្រសួងស្ថាប័ន
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង
  មានលេខាធិការដ្ឋានមួយ ជាជំនួយការ
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខ័ណ្ឌ
  មានលេខាធិការដ្ឋានមួយ ជាជំនួយការ

អង្គការលេខរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៣

## ខុទ្ទកាល័យប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**មាត្រា១០ :** ខុទ្ទកាល័យ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទទួលបន្ទុកសំរួលរាល់កិច្ចការប្រធាន ជាក់ស្តែង អនុប្រធានទី១ ជំនួសមុខឱ្យប្រធាន ដោះស្រាយគ្រប់កិច្ចការ និងប្រតិបត្តិការផ្ទាល់ ដោយសរុបរាយការណ៍ជូន ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រីឯអ្នកជំនួយការក៏ត្រូវបំរើអោយការងារអនុប្រធានទី១។

ភារកិច្ចរបស់ខុទ្ទកាល័យមានជាអាទិ៍ :

- រ៉ាប់រង ទំនាក់ទំនងការងារ
- ផ្តល់យោបល់ជូនប្រធាន ឬអនុប្រធានទី១ គ.ជ.គ.ម ចំពោះកិច្ចការទូទៅ និងចំពោះសំណុំរឿងទាំងឡាយដែលប្រធាន ឬអនុប្រធានទី១ បានប្រគល់អោយពិនិត្យ ។
- ចែកផ្សាយអំពីគោលការណ៍ណែនាំ របស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- រៀបចំ កាលវិភាគរបស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- រៀបចំសម័យប្រជុំការងារ គ.ជ.គ.ម ។
- បញ្ជូនបញ្ហាប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- តាមដានការអនុវត្តន៍បទបញ្ជារបស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។

## ជំពូកទី៤
## អគ្គលេខាធិការដ្ឋាន

**មាត្រា១១ :** អគ្គលេខាធិការដ្ឋានមានភារកិច្ចជាសេនាធិការ ឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយលើការងារ :

- ធានានិរន្តរភាពនៃដំណើរការរដ្ឋបាលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- សិក្សាស្រាវជ្រាវតំបន់ងាយរងគ្រោះដោយទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និងមុខសញ្ញាគ្រោះថ្នាក់ដទៃទៀត ដោយរៀបចំផែនការ ត្រៀមបង្ការ ឆ្លើយតបសង្គ្រោះបន្ទាន់ ។
- ណែនាំការងារ ជំនាញបច្ចេកទេសដល់លេខាធិការដ្ឋាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ សហគមន៍ជួយសង្គ្រោះ ដើម្បីជាមូលដ្ឋានក្នុងការប្រមូលទិន្នន័យគ្រោះមហន្តរាយ សំរាប់ធ្វើការវាយតំលៃប៉ាន់ស្មាន អំពីការខូចខាត និងតំរូវការ និងរៀបចំកម្មវិធីស្តារ និងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដែលខូចខាត ដោយសំរបសំរួលការងារជាមួយស្ថាប័ននានា ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធ ។
- លើកផែនការ បណ្តុះបណ្តាលជំនាញបច្ចេកទេស ដល់បុគ្គលិកគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់កណ្តាល ខេត្ត-ក្រុង. ស្រុក-ខ័ណ្ឌ និងសហគមន៍ជួយសង្គ្រោះ ក្នុងក្របខ័ណ្ឌបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេស ។
- សំរបសំរួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ អាជ្ញាធរដែនដី ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីជំលៀសប្រជាជន

ងាយរងគ្រោះ ទៅទីសុវត្ថិភាព ការពារសន្តិសុខ អប់រំសាធារណៈ ឆ្លើយតបសង្គ្រោះបន្ទាន់ និងរៀបចំកម្មវិធីផ្សេង ៗ ។

លើកយោបល់រាល់លិខិតស្នាមពាក់ព័ន្ធ ការងារគ្រប់គ្រងគ្រោះមហន្តរាយ និងលិខិតព្រមព្រៀង បូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ មាននាយកដ្ឋានចំនួន ៥ ដូចមានក្នុងមាត្រាខាងក្រោម :

**មាត្រា ១២ :** នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ច :

- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាល របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- សរុបរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- គ្រប់គ្រងរដ្ឋបាល ផ្នែកមន្ត្រីរាជការ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ។
- ប្រមូលផ្តុំតំរូវការ លើកគំរោងថវិកា ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ ។
- សំរបសំរួលជំពូក ថវិកា និងរាល់ចំណាយ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិសំភារៈ និង បញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ១៣:** នាយកដ្ឋាន ពត៌មាន និងទំនាក់ទំនង មានភារកិច្ច :

- ធ្វើការតាមដាន ពត៌មានអាកាសធាតុ ស្ថានភាពឧតុនិយម ជលសាស្ត្រ ។
- និពន្ធ និងចងក្រងដំណឹងអត្ថបទ ស្តីពីគ្រោះមហន្តរាយ ។
- ចេញផ្សាយនូវពត៌មាន ស្តីពីគ្រោះមហន្តរាយផ្សេងៗក្នុង និងក្រៅប្រទេស តាមរយៈព្រឹត្តិប័ត្រ និងប្រព័ន្ធផ្សាយពត៌មាន ។
- ផលិតផ្ទាំងរូបភាព សៀវភៅរូបថត ពីគ្រោះមហន្តរាយ ។
- រៀបចំរបាយការណ៍ ស្តីពីស្ថានភាពជលសាស្ត្រ ឧតុនិយម ដោយសហការជាមួយក្រសួងស្ថាប័នជំនាញ និងប្រកាសជូនដំណឹងជាមុននូវគ្រោះអាសន្ន កង្វះខាត និងវិធានការណ៍ ។
- ទំនាក់ទំនងការងារគ្រោះមហន្តរាយ ជាមួយបរទេស និងអង្គការអន្តរជាតិ ។

**មាត្រា ១៤ :** នាយកដ្ឋាន ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ មានភារកិច្ច :

- រៀបចំ បង្កើតឡើងនូវវេទនាសម្ព័ន្ធបញ្ជាការ ក្នុងសកម្មភាពសង្គ្រោះបន្ទាន់ ស្របតាមគោលនយោបាយជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅពេលទទួលបានពត៌មាន ព្យាករណ៍ស្តីពីគ្រោះមហន្តរាយ ។

- រៀបចំផែនការត្រៀមបង្ការ កាត់បន្ថយ សង្គ្រោះបន្ទាន់ កម្មវិធីស្តារលទ្ធភាពពលកម្ម និង ការស្តារឡើងវិញ ។
- សំរបសំរួលជាមួយក្រសួងពាក់ព័ន្ធ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្រាវជ្រាវមុខសញ្ញាគ្រោះថ្នាក់ សេវាកម្ម សង្គ្រោះបន្ទាន់ ការពារសុវត្ថិភាព សន្តិសុខ ជំលៀស ទីជំរក ។
- ចុះស្រង់ស្ថិតិការខូចខាត និងសេចក្តីត្រូវការ និងដឹកនាំប្រតិបត្តិការពេលមានគ្រោះអាសន្ន ។

**មាត្រា ១៥ :** នាយកដ្ឋាន ត្រៀមរៀបចំ និងបណ្តុះបណ្តាលមានភារកិច្ច :

- ត្រៀមរៀបចំមូលដ្ឋានសំភារៈ ត្រៀមផ្គត់ផ្គង់ផ្សេងៗ សំរាប់ឆ្លើយតបសង្គ្រោះបន្ទាន់ ពេលមានគ្រោះអាសន្ន ។
- កសាងផែនការ កម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស ដែលបំរើឱ្យការងារគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ មូលដ្ឋាន ។
- ជ្រើសរើសបេក្ខជន ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ។
- អប់រំ ផ្សព្វផ្សាយ អំពីការងារត្រៀមរៀបចំបង្ការគ្រោះមហន្តរាយ ដល់សហគមន៍មូលដ្ឋាន និងប្រជាជនរងគ្រោះ ។
- ចែកផ្សាយឯកសាររូបភាពដែលពាក់ព័ន្ធដល់ការងារបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយ ។

**មាត្រា ១៦:** នាយកដ្ឋាន សំរបសំរួលការងារ ឧបទ្ទវហេតុ យន្តហោះ នាវា មានភារកិច្ច :

- សំរបសំរួលការងារជាមួយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពស្របទៅតាមនិតិវិធីដែលបានរៀបចំឡើង ។
- រៀបចំគំរោងផែនការជូន អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ក្នុងការប្រើប្រាស់មធ្យោបាយ និងកំលាំងអន្តរាគមន៍រុករក និងសង្គ្រោះ ។
- ទទួល និងបញ្ជូនពត៌មាន ស្តីពីឧបទ្ទវហេតុយន្តហោះ នាវា និងស្នើសុំគោលការណ៍ អនុវត្តបទបញ្ជា និងការណែនាំពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទាក់ទងនឹងការសំរបសំរួល រុករក និងសង្គ្រោះ ។
- ធ្វើសេចក្តីប្រកាសជាផ្លូវការ ពីទីកន្លែងកើតឧបទ្ទវហេតុយន្តហោះ នាវា នៅពេលពត៌មាន ជាក់លាក់ត្រូវបានផ្ទៀងផ្ទាត់
- រៀបចំបែបបទ សំរបសំរួលជាមួយប្រទេសជិតខាង ដើម្បីរួបសហការដោះស្រាយការងាររុករក និងសង្គ្រោះ ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការសំរបសំរួលរុករក និងសង្គ្រោះ ។

សហការជាមួយមជ្ឈមណ្ឌល សំរបសំរួល សង្គ្រោះ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កំណត់បេសកកម្ម រុករក និងសង្គ្រោះ ។

## ជំពូកទី ៥
## ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួង ស្ថាប័ន

**មាត្រា ១៧ :** ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងស្ថាប័ន ត្រូវបានបង្កើតឡើងដោយ ក្រសួងស្ថាប័ននីមួយៗផ្ទាល់ ដើម្បីបង្កើនការលើកតំពស់ស្មារតី ភាពម្ចាស់ការចូលរួមដោះស្រាយគ្រោះមហន្តរាយ និងមានភារកិច្ចទទួលខុសត្រូវ ដើម្បីធ្វើការសំរបសំរួល រាល់សកម្មភាពក្នុងការត្រៀមរៀបចំ ឆ្លើយតបគ្រោះមហន្តរាយ និងស្តារឡើងវិញ ។

## ជំពូកទី ៦
## គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង

**មាត្រា ១៨:** នៅតាមខេត្ត-ក្រុងនីមួយៗមាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង ដែលមានសមាសភាព :

- អភិបាល ខេត្ត-ក្រុង ជាប្រធាន
- អភិបាលរង ខេត្ត-ក្រុង ជាអនុប្រធាន
- ប្រធាន មន្ទីរជុំវិញ ខេត្ត-ក្រុង
  និង នាយកសាខាកាកបាទក្រហម ខេត្ត-ក្រុង ជាសមាជិក

**មាត្រា ១៩:** គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង មានភារកិច្ច :

- អនុវត្តគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។
- រៀបចំធ្វើការណែនាំ និងគាំទ្រដល់សកម្មភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខ័ណ្ឌ ។
- ផ្តល់យោបល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំពោះសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធកាកបាទក្រហមកម្ពុជា ការឧបត្ថម្ភរបស់អង្គការជាតិ និងអន្តរជាតិ ដែលចូលរួមទប់ស្កាត់ ត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងស្តារឡើង វិញ ។
- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការខូចខាត និងធ្វើសំណើសុំឧបត្ថម្ភថវិកា សំភារៈបរិក្ខារមធ្យោបាយ និងកំលាំងអន្តរាគមន៍ សំរាប់ដោះស្រាយក្នុងពេលមានគ្រោះមហន្តរាយ ។

- អនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងជំនាញបច្ចេកទេស ដល់មន្ត្រីរាជការ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តកម្មវិធីអប់រំ ជាសាធារណៈនៅក្នុងសហគមន៍ ។

**មាត្រា ២០ :** គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង មានលេខាធិការដ្ឋាន ជាសេនាធិការសំរាប់ធានានិរន្តរភាពការងារ ដែលដឹកនាំដោយនាយខុទ្ទកាល័យសាលាខេត្ត-ក្រុង ធ្វើជាលេខាអចិន្ត្រៃយ៍ និងជំនួយការ មួយចំនួន ជួយការងារ តាមការចាំបាច់ ។

## ជំពូកទី ៧

## គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ

**មាត្រា ២១ :** នៅតាមស្រុក-ខ័ណ្ឌ នីមួយៗមានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាព :

- អភិបាល ស្រុក-ខ័ណ្ឌ ជាប្រធាន
- អភិបាលរង ស្រុក-ខ័ណ្ឌ ជាអនុប្រធាន
- ប្រធានការិយាល័យជុំវិញស្រុក-ខ័ណ្ឌ
  ប្រធានអនុសាខាកាកបាទក្រហម ស្រុក-ខ័ណ្ឌ ជាសមាជិក

**មាត្រា ២២ :** គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខ័ណ្ឌ មានភារកិច្ច :

- អនុវត្តគោលនយោបាយជាតិ ដែលពាក់ព័ន្ធក្នុងការងារគ្រប់គ្រងគ្រោះ មហន្តរាយ
- ផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង អំពីស្ថានភាពថ្មីៗ ។
- ជ្រើសរើសមន្ត្រីដើម្បីចូលរួម ក្នុងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ រឺខេត្ត-ក្រុង ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។
- រៀបចំ និងផ្សព្វផ្សាយពត៌មាន ដល់សាធារណជន អំពីគ្រោះមហន្តរាយ ។
- បញ្ជូនរបាយការណ៍ ស្តីពីសេចក្តីត្រូវការទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្តីពីការខូចខាត និងតំរូវការផ្សេងៗ ។
- ដឹកនាំប្រតិបត្តិការ ក្នុងពេលមានគ្រោះមហន្តរាយ រួមមានជំនួយសង្គ្រោះ ការជំលៀសការផ្តល់ទីជំរក និងការផ្តល់ជំនួយសុខាភិបាល ។
- បញ្ជូនរបាយការណ៍សរុប ស្តីពីប្រតិបត្តិការ ជំនួយសង្គ្រោះទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង ។

**មាត្រា ២៣:** គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ មានលេខាធិការដ្ឋាន ជាសេនាធិការសំរាប់ធានានិរន្តរភាពការងារ ដែលដឹកនាំដោយប្រធានមន្ទីរ សាលាស្រុក-ខ័ណ្ឌ ធ្វើជាលេខាអចិន្ត្រៃយ៍ និងជំនួយការមួយចំនួន ជួយការងារតាមការចាំបាច់ ។

## ជំពូកទី ៨
## អង្គភាព ត្រួតពិនិត្យ ហិរញ្ញវត្ថុ

**មាត្រា ២៤ :** អង្គភាព ត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជា កំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័ន ត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា តាមបណ្តាក្រសួង ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ២៥ :** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា ២៦ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ២៨ :** អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេច នាយករដ្ឋមន្ត្រី

អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**ញឹម វណ្ណដា**

*កន្លែងទទួល:*

*-ក្រសួង ព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋាន រដ្ឋសភា*

*-ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី*

*-ដូចក្នុងមាត្រា ២៧*

*-រាជកិច្ច*

*-កាលប្បវត្តិ-ឯកសារ*

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៣០ អនក្រ.បក
ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០០២

## អង្គការលេខ
## របស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ




My docu/Secretary General

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៧០ អនក្រ.បក

ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០០១

# អង្គការលេខ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
# ( គ.ជ.ក.ម NCDM )




Folder: Schedule/furniture of ncdm